# អ្វីៗដែលអ្នកត្រូវដឹងអំពីការចុះឈ្មោះបោះឆ្នោត

# ឆ្លើយសំណួរនៃការចុះឈ្មោះបោះឆ្នោតទាំងនេះនៅខាងក្នុង

**ការចុះឈ្មោះបោះឆ្នោត**

តើខ្ញុំមានសិទ្ធិចុះឈ្មោះ?

តើខ្ញុំបានបាត់បង់សិទ្ធិពីការចុះឈ្មោះ?

ហេតុអ្វីខ្ញុំគួរចុះឈ្មោះ?

តើខ្ញុំចុះឈ្មោះដូចម្តេច?

កន្លែងណាដែលខ្ញុំទទួលទម្រង់បែបបទនៃការចុះឈ្មោះ?

តើខ្ញុំអាចចុះឈ្មោះដោយប្រើអ៊ីនធឺណិតដែរឬទេ?

តើខ្ញុំអាចធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់ខ្ញុំដោយប្រើអ៊ីនធឺណិតដែរឬទេ?

តើខ្ញុំអាចចុះឈ្មោះ មុនពេលខ្ញុំមានអាយុ 18 ឆ្នាំដែរឬទេ?

ខ្ញុំពិការ។ តើខ្ញុំអាចមានជំនួយជាមួយនឹងការចុះឈ្មោះដែរឬទេ?

ខ្ញុំមានគ្រួសារ ឬ មិត្តនៅបរទេស។ តើខ្ញុំអាចចុះឈ្មោះពួកគេដែរឬទេ?

តើអ្វីជាបញ្ជីដែលមិនបានផ្សព្វផ្សាយ?

តើអ្វីកើតឡើងចំពោះទម្រង់បែបបទនៃការចុះឈ្មោះរបស់ខ្ញ បន្ទាប់ពីខ្ញុំបានផ្ញើវាត្រឡប់មកវិញ?

ព័ត៌មានអ្វីដែលខ្ញុំត្រូវផ្តល់ឲ្យ?

**ការចុះឈ្មោះរបស់**

ជម្រើសនៃការបោះឆ្នោតរបស់ម៉ៅរី?

ខ្ញុំគឺជាជនជាតិម៉ៅរីញូវសេឡែន។ តើខ្ញុំជ្រើសរើសបញ្ជីណាត្រូវស្ថិតនៅលើដូចម្តេច?

ចុះបើខ្ញុំគឺជាម៉ៅរីដែលចុះឈ្មោះជាលើកដំបូង?

តើជម្រើសបោះឆ្នោតម៉ៅរីធ្វើឡើងញឹកញាប់ប៉ុណ្ណា?

ខ្ញុំគឺជាជនជាតិប៉ូលីនេស៊ីរស់លើកោះផាស៊ីហ្វិក។ តើខ្ញុំអាចស្ថិតលើបញ្ជីម៉ៅរីដែរឬទេ?

**បញ្ជីបោះឆ្នោត**

តើអ្វីជាបញ្ជីបោះឆ្នោតរដ្ឋសភា?

តើកន្លែងណាដែលខ្ញុំអាចឃើញបញ្ជីបោះឆ្នោត?

តើព័ត៌មានបោះឆ្នោតប្រើសម្រាប់អ្វី?

**ការរក្សាព័ត៌មានលម្អិត**

**នៃការចុះឈ្មោះរបស់អ្នកឲ្យទាន់សម័យ**

តើខ្ញុំធ្វើអ្វី បើខ្ញុំប្តូរអាសយដ្ឋានរបស់ខ្ញុំ?

តើខ្ញុំត្រូវធ្វើអ្វី បើខ្ញុំប្តូរឈ្មោះ ឬ មុខរបររបស់ខ្ញុំ?

តើអ្វីកើតឡើង បើខ្ញុំបានភ្លេចធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់ខ្ញុំ?

**យុទ្ធនាការធ្វើបច្ចុប្បន្នភាពនៃការចុះឈ្មោះ**

អ្វីជាយុទ្ធនាការធ្វើបច្ចុប្បន្នភាពនៃការចុះឈ្មោះ?

តើខ្ញុំធ្វើអ្វី នៅពេលមានយុទ្ធនាការធ្វើបច្ចុប្បន្នភាពនៃការចុះឈ្មោះ?

តើអ្វីកើតឡើង បើខ្ញុំមិនផ្ញើត្រឡប់ទៅវិញនូវទម្រង់បែបបទបច្ចុប្បន្នភាពនៃការចុះឈ្មោះរបស់ខ្ញុំ?

ចុះបើខ្ញុំទទួលទម្រង់បែបបទបច្ចុប្បន្នភាពនៃការចុះឈ្មោះសម្រាប់នរណាម្នាក់ដែលលែងរស់នៅអាសយដ្ឋាននោះ?

ចុះបើខ្ញុំមិនទទួលទម្រង់បែបបទបច្ចុប្បន្នភាពនៃការចុះឈ្មោះ?

## ព្រំដែននៃការបោះឆ្នោត

ខ្ញុំមិនបានផ្លាស់ទីលំនៅទេ ប៉ុន្តែខ្ញុំត្រូវបានដាក់ក្នុងកន្លែងបោះឆ្នោតផ្សេង។ ហេតុអ្វី?

## ការបោះឆ្នោតផ្សេងទៀត

តើអ្វីជាការបោះឆ្នោតពិសេសនៃរដ្ឋសភា?

អ្វីជាបោះឆ្នោតក្នុងស្រុក?

តើខ្ញុំទទួលសិទ្ធិបោះឆ្នោតក្នុងប្រជាមតិដែលផ្តួចផ្តើមដោយពលរដ្ឋ និង/ឬ ប្រជាមតិដែលផ្តួចផ្តើមដោយរដ្ឋាភិបាលដែរឬទេ?

## ព័ត៌មានបន្ថែម

តើខ្ញុំទទួលព័ត៌មានបន្ថែមដូចម្តេច?

តើខ្ញុំអាចទទួលព័ត៌មាននេះជាភាសាផ្សេងទៀតដែរឬទេ?

អ្នកត្រូវតែបានចុះឈ្មោះដើម្បីបោះឆ្នោតរដ្ឋសភានៃញូវសេឡែន

យ៉ាងហោចណាស់ ម្តងក្នុងពេលបីឆ្នាំ ញូវសេឡែនធ្វើការបោះឆ្នោតទូទៅដើម្បីជ្រើសរើសរដ្ឋសភា និង រដ្ឋាភិបាលថ្មី។ មានកន្លែងបោះឆ្នោតទូទៅ និង ម៉ោរី។ កន្លែងបោះឆ្នោតនីមួយៗមានបញ្ជីនៃអ្នកដែលបានចុះឈ្មោះបោះឆ្នោត។ បើអ្នកមានអាយុ 18 ឆ្នាំ ឬ ច្រើនជាងនេះ និង មានសិទ្ធិចុះឈ្មោះ ច្បាប់ចែងថា អ្នកត្រូវតែស្ថិតនៅលើបញ្ជី។ បើអ្នកមានអាយុ 17 ឆ្នាំ អ្នកអាចចុះឈ្មោះបណ្តោះអាសន្ន។ នៅពេលបានចុះឈ្មោះ អ្នកត្រូវតែរក្សាឲ្យព័ត៌មានលម្អិតរបស់អ្នកទាន់សម័យ។ បញ្ជិកាក្រឹតនៃអ្នកបោះឆ្នោត ដែលធ្វើការឲ្យ NEW ZEALAND POST LTD មើលថែបញ្ជីនោះ។

## សេចក្ដីណែនាំ

### ការចុះឈ្មោះបោះឆ្នោត

### តើខ្ញុំមានសិទ្ធិចុះឈ្មោះ?

អ្នកទទួលសិទ្ធិ និង ត្រូវតែចុះឈ្មោះដោយស្របច្បាប់ បើ៖

- ☐ អ្នកគឺជាពលរដ្ឋញូវសេឡេន ឬ អ្នកស្នាក់នៅអចិន្ត្រៃយ៍នៅញូវសេឡេន និង
- ☐ អ្នកមានអាយុ 18 ឆ្នាំ ឬ ច្រើនជាងនេះ និង
- ☐ អ្នកបានរស់នៅញូវសេឡេនលើសពីមួយឆ្នាំបន្តបន្ទាប់គ្នា នៅពេលណាមួយ និង
- ☐ អ្នកមិនបាត់បង់សិទ្ធិ។

### តើខ្ញុំបានបាត់បង់សិទ្ធិពីការចុះឈ្មោះ?

អ្នកមិនអាចចុះឈ្មោះឡើយ បើ៖

- ☐ អ្នកគឺជាពលរដ្ឋញូវសេឡេនដែលនៅក្រៅញូវសេឡេន និង មិនបានស្ថិតនៅញូវសេឡេនក្នុងពេល 3 ឆ្នាំចុងក្រោយ។
- ☐ អ្នកគឺជាអ្នកស្នាក់នៅអចិន្ត្រៃយ៍នៅញូវសេឡេនដែលនៅក្រៅញូវសេឡេន និង មិនបានស្ថិតនៅញូវសេឡេនក្នុងពេល 12 ខែចុងក្រោយ។

(សម្គាល់៖ មានការលើកលែងចំពោះបញ្ញត្តិទាំងពីរខាងលើ។ ឧទាហរណ៍ មន្ត្រីបម្រើការសាធារណៈ ឬ សមាជិកនៃកងកម្លាំងការពារជាតិ ដែលមានភារកិច្ចស្ថិតនៅក្រៅញូវសេឡេន ព្រមទាំងសមាជិកនៃគ្រួសាររបស់ពួកគេ។)

មានមូលដ្ឋានផ្សេងទៀតនៃការបាត់បង់សិទ្ធិដែលប៉ះពាល់ដល់ចំនួនមនុស្សមួយភាគតិច។ បញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតទទួលដំណឹងអំពីមនុស្សដែលស្ថិតនៅក្រោមមូលដ្ឋានទាំងនោះ។ បើអ្នកមានសំណួរ ឬ

ការព្រួយបារម្ភណាមួយអំពីមូលដ្ឋានផ្សេងទៀតចំពោះការបាត់បង់សិទ្ធិ សូមហៅទូរស័ព្ទទៅលេខ 0800 ENROL NOW (0800 36 76 56) ឬ មើលវិបសៃរបស់យើង – elections.org.nz។

### ហេតុអ្វីខ្ញុំគួរចុះឈ្មោះ?

អ្នកត្រូវតែចុះឈ្មោះ បើអ្នកទទួលសិទ្ធិក្នុងការចុះឈ្មោះ។ ការចុះឈ្មោះផ្ដល់ឲ្យអ្នកនូវឱកាសដើម្បីបោះឆ្នោត។ ការបោះឆ្នោតគឺជាឱកាសរបស់អ្នកក្នុងការបញ្ចេញមតិរបស់អ្នកអំពីមនុស្សណា និង

គណបក្សនយោបាយណាដែលត្រូវជ្រើសរើសចូលទៅក្នុងរដ្ឋសភាញូវសេឡេន នៅក្នុងការបោះឆ្នោតទូទៅនីមួយៗ។ អ្នកក៏នឹងមានឱកាសដើម្បីបោះឆ្នោតក្រុមប្រឹក្សាស្រុក និង ការបោះឆ្នោតគណៈសុខភាពស្រុក ព្រមទាំងប្រជាមតិ ឬ ការបោះឆ្នោតនានាផងដែរ។

### តើខ្ញុំចុះឈ្មោះដូចម្ដេច?

អ្នកគ្រាន់តែបំពេញទម្រង់បែបបទនៃការចុះឈ្មោះដែលមានចំណងជើងថា “Enrolling to vote: Application” (“ការចុះឈ្មោះបោះឆ្នោត៖ ការដាក់ពាក្យសុំ”)។ អ្នកត្រូវតែដាក់ពាក្យសុំចុះឈ្មោះលើបញ្ជីបោះឆ្នោត

សូម្បីអ្នកមិនចង់បោះឆ្នោត។

បើអ្នកគឺជាជនជាតិម៉ោរីញូវសេឡេន ឬ កូនចៅរបស់ម៉ោរីញូវសេឡេន និង ចុះឈ្មោះជាលើកដំបូង អ្នកក៏អាចប្រើពាក្យសុំដើម្បីប្រាប់ថាបញ្ជីណាដែលត្រូវស្ថិតនៅលើ។ អ្នកអាចជ្រើសរវាងបញ្ជីម៉ោរី ឬ ទូទៅ។

### កន្លែងណាដែលខ្ញុំទទួលទម្រង់បែបបទនៃការចុះឈ្មោះ?

- ☐ បំពេញ និង ផ្ញើតាមប្រៃសណីយ៍នូវគូប៉ុង (មានតែភាសាអង់គ្លេសប៉ុណ្ណោះ) នៅខាងខ្នងនៃកូនសៀវភៅនេះ នោះយើងនឹងផ្ញើជូនអ្នកមួយ។
- ☐ ឯកសារទាំងនោះគឺឥតគិតថ្លៃពី PostShop ណាមួយ។
- ☐ ហៅទូរស័ព្ទមកយើងដោយឥតបង់ប្រាក់តាមលេខ 0800 ENROL NOW
  (0800 36 76 56)នោះយើងនឹងផ្ញើជូនអ្នកមួយ។
- ☐ ផ្ញើសារឥតគិតថ្លៃ ដោយសរសេរឈ្មោះ និង អាសយដ្ឋានរបស់អ្នក ទៅលេខ 3676
  នោះយើងនឹងផ្ញើជូនអ្នកមួយ។
- ☐ ស្នើសុំ ឬ បោះពុម្ពឯកសារមួយច្បាប់ពីវិបសៃរបស់យើង –
  elections.org.nz.

បន្ទាប់ពីអ្នកបានបំពេញទម្រង់បែបបទនេះហើយ សូមដាក់វានៅ PostShop ណាមួយ ឬ ផ្ញើវាតាមប្រៃសណីយ៍ (មិនត្រូវការតែមប្រៃសណីយ៍) ទៅ៖

FREEPOST 2 ENROL

ELECTORAL ENROLMENT CENTRE

P O BOX 190, WELLINGTON 6140

## តើខ្ញុំអាចចុះឈ្មោះដោយប្រើអ៊ីនធឺណិតដែរឬទេ?

បាទ/ចាស អ្នកគ្រាន់តែទៅវិបសៃរបស់យើង – elections.org.nz – និង ចុចប៊ូតុង enrol, check or update។ ធ្វើតាមជំហានទាំងឡាយដើម្បីបំពេញព័ត៌មានលម្អិតនៃការចុះឈ្មោះរបស់អ្នក។ រួចហើយ អ្នកអាចទាញយក និង បោះពុម្ពទម្រង់បែបបទនៃការចុះឈ្មោះដែលបានបំពេញព័ត៌មានលម្អិតហើយ, ចុះហត្ថលេខាលើវា និង ផ្ញើវា ដើម្បីបំពេញដំណើរការនោះ។

ជម្រើសផ្សេងទៀត អ្នកអាចប្រគល់ប្រតិបត្តិការនោះ បន្ទាប់មកយើងនឹងផ្ញើទម្រង់បែបបទនៃការចុះឈ្មោះជាបុគ្គលមុនបោះពុម្ពឲ្យអ្នកពិនិត្យ, ចុះហត្ថលេខា និង ផ្ញើត្រឡប់មកវិញ។
អ្នកក៏អាចពិនិត្យព័ត៌មានលម្អិតនៃការចុះឈ្មោះរបស់អ្នកលើបណ្ដាញអ៊ីនធឺណិតតាមវិបសៃនោះផងដែរ។

## តើខ្ញុំអាចធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់ខ្ញុំដោយប្រើអ៊ីនធឺណិតដែរឬទេ?

បុគ្គលម្នាក់អាចធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតនៃការចុះឈ្មោះរបស់ពួកគេតាមអេឡិចត្រូនិក នៅពេលពួកគេបានបំពេញ (ហើយបញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតបានទទួល) ទម្រង់បែបបទ ‘Enrolling to vote: Application’ (‘ការចុះឈ្មោះបោះឆ្នោត៖ ការដាក់ពាក្យសុំ’) ដែលបង្ហាញថាពួកគេចង់ចូលរួមក្នុងសេវានេះ។ អាសយដ្ឋានអ៊ីមែលរបស់អ្នកដាក់ពាក្យសុំក៏ត្រូវការផងដែរ។

ការធ្វើបច្ចុប្បន្នភាពតាមអេឡិចត្រូនិកនូវព័ត៌មានលម្អិតនៃការចុះឈ្មោះអាចធ្វើបានតាមការចុះឈ្មោះចូល igovt ដែលអនុញ្ញាតនូវការប្រើព័ត៌មានលម្អិតនៃការចុះឈ្មោះចូលដូចគ្នា ដើម្បីចូលប្រើសេវាលើបណ្ដាញអ៊ីនធឺណិតរបស់រដ្ឋាភិបាលជាច្រើន – igovt មានសុវត្ថិភាព និង រក្សាភាពឯកជនរបស់អ្នក។

នៅពេលការចុះឈ្មោះរបស់អ្នកត្រូវបានដំណើរការ អ្នកនឹងត្រូវបានទាក់ទងតាមអាសយដ្ឋានអ៊ីមែលដែលបានផ្ដល់ឲ្យលើទម្រង់បែបបទនៃពាក្យសុំរបស់អ្នក ដើម្បីបំពេញការចុះបញ្ជីជាមួយសេវាលើបណ្ដាញអ៊ីនធឺណិតនៃការចុះឈ្មោះបោះឆ្នោត។
ការណ៍នេះនឹងតម្រូវឲ្យអ្នករៀបចំការចុះឈ្មោះចូល igovt ឬ ប្រើការចុះឈ្មោះចូល igovt ដែលមានស្រាប់របស់អ្នក បើអ្នកមានមួយ។

បើអ្នកសម្រេចថាមិនចង់ធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតនៃការចុះឈ្មោះរបស់អ្នកតាមអេឡិចត្រូនិកទេ អ្នកត្រូវប្រាប់បញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតថាអ្នកលែងចូលរួមក្នុងជម្រើសនៃប្រតិបត្តិការតាមអេឡិចត្រូនិកទៀតហើយ។
ការចូលប្រើកំណត់ត្រានៃការចុះឈ្មោះរបស់អ្នកនឹងកែទៅតាមនោះ។

## តើខ្ញុំអាចចុះឈ្មោះ មុនពេលខ្ញុំមានអាយុ 18 ឆ្នាំដែរឬទេ?

បាទ/ចាស នៅពេលអ្នកមានអាយុ 17 ឆ្នាំ អ្នកអាចធ្វើ “ការចុះឈ្មោះបណ្ដោះអាសន្ន” ភ្លាមៗ ដោយការបំពេញទម្រង់បែបបទនៃការចុះឈ្មោះ។ នៅពេលអ្នកមានអាយុ 18 ឆ្នាំ អ្នកនឹងត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិ។

ព័ត៌មានបន្ថែមអាចរកបាននៅក្នុងកូនសៀវភៅរបស់យើងដែលមានចំណងជើងថា “Enrolling to vote before you’re 18” (“ការចុះឈ្មោះបោះឆ្នោត មុនពេលអ្នកមានអាយុ 18 ឆ្នាំ”)។ អាចរកបាននៅ PostShop ណាមួយ ឬ ហៅទូរស័ព្ទទៅលេខ 0800 ENROL NOW (0800 36 76 56) ដើម្បីឲ្យគេផ្ញើឲ្យមួយ។

## ខ្ញុំពិការ។ តើខ្ញុំអាចមានជំនួយជាមួយនឹងការចុះឈ្មោះដែរឬទេ?

បើអ្នកពិការខាងរាងកាយ និង ត្រូវការជំនួយក្នុងការបំពេញ និង ត្រឡប់ទម្រង់បែបបទនៃការចុះឈ្មោះសរបស់អ្នកមកវិញ នេះគឺអ្វីដែលអ្នកអាចធ្វើបាន៖

- អ្នកអាចឲ្យអ្នកបោះឆ្នោតដែលបានចុះបញ្ជីរួចបំពេញ និង ចុះហត្ថលេខាលើទម្រង់បែបបទរបស់អ្នក។ ពួកគេត្រូវតែសរសេរលើទម្រង់បែបបទរបស់អ្នកជាប់នឹងហត្ថលេខារបស់ពួកគេថា “Elector Physically Disabled – signed by their direction”។
- ឬ អ្នកអាចឲ្យបុគ្គលដែលមានសិទ្ធិតំណាងឲ្យអ្នកបំពេញ និង ចុះហត្ថលេខាលើទម្រង់បែបបទ។ ពួកគេត្រូវតែសរសេរលើទម្រង់បែបបទជាប់នឹងហត្ថលេខារបស់ពួកគេថា “Elector Physically Disabled – Power of Attorney”។

បើសមាជិកនៃគ្រួសាររបស់អ្នកអសមត្ថភាពខាងផ្លូវចិត្ត អ្នកអាចចុះឈ្មោះឲ្យពួកគេបាន។ ហៅទូរស័ព្ទមកយើងដោយឥតបង់ប្រាក់តាមលេខ 0800 ENROL NOW (0800 36 76 56) សម្រាប់ព័ត៌មានលម្អិត។

## ខ្ញុំមានគ្រួសារ ឬ មិត្តនៅបរទេស។ តើខ្ញុំអាចចុះឈ្មោះពួកគេដែរឬទេ?

បាទ/ចាស។ ដោយសន្មតថាពួកគេនៅតែទទួលសិទ្ធិចុះឈ្មោះ អ្នកអាចបំពេញទម្រង់បែបបទនៃការចុះឈ្មោះរបស់ពួកគេ។ នេះគឺអ្វីដែលអ្នកអាចធ្វើ៖

- បើអ្នកគឺជាអ្នកបោះឆ្នោតដែលបានចុះបញ្ជី អ្នកអាចបំពេញក្នុងទម្រង់បែបបទរបស់ពួកគេ និង ចុះហត្ថលេខាលើទម្រង់បែបបទនោះ។ អ្នកត្រូវតែសរសេរលើទម្រង់បែបបទរបស់ពួកគេជាប់នឹងហត្ថលេខារបស់អ្នកថា “Elector Overseas – signed by their direction”។
- ឬ បើអ្នកមានសិទ្ធិតំណាងពីពួកគេ អ្នកអាចបំពេញ និង ចុះហត្ថលេខាលើទម្រង់បែបបទរបស់ពួកគេ។ អ្នកត្រូវតែសរសេរលើទម្រង់បែបបទជាប់នឹងហត្ថលេខារបស់អ្នកថា “Elector Overseas – Power of Attorney”។

## តើអ្វីជាបញ្ជីដែលមិនបានផ្សព្វផ្សាយ?

បើអ្នកជឿថាការដាក់ព័ត៌មានលម្អិតរបស់អ្នកលើបញ្ជីបោះឆ្នោតដែលបានបោះពុម្ពអាចគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នក អ្នកអាចស្នើសុំជាពិសេសមិនឲ្យបង្ហាញព័ត៌មាននោះលើបញ្ជីដែលបានបោះពុម្ព។ អ្នកនឹងត្រូវដាក់ពាក្យសុំដាច់ដោយឡែកសម្រាប់ករណីនេះ និង ផ្ដល់ព័ស្តុតាងខ្លះអំពីស្ថានភាពរបស់អ្នក ដូចជា ការបញ្ជាឲ្យការពារ, ការបញ្ជាឲ្យត្រួតត្រា ឬ សេចក្ដីប្រកាសតាមផ្លូវច្បាប់ពីតម្រួត។

ព័ត៌មានបន្ថែម និង ទម្រង់បែបបទនៃការដាក់ពាក្យសុំអាចរកបានក្នុងកូនសៀវភៅរបស់យើងដែលមានចំណងជើងថា “Everything you need to know about the unpublished electoral roll” (“អ្វីៗដែលអ្នកត្រូវដឹងអំពីបញ្ជីបោះឆ្នោតដែលមិនបានផ្សព្វផ្សាយ”)។ អាចរកបាននៅ PostShop ណាមួយ ឬ ហៅទូរស័ព្ទទៅលេខ 0800 ENROL NOW (0800 36 76 56) ដើម្បីឲ្យគេផ្ញើឲ្យមួយ។

## តើអ្វីកើតឡើងចំពោះទម្រង់បែបបទនៃការចុះឈ្មោះរបស់ខ្ញុំ បន្ទាប់ពីខ្ញុំបានផ្ញើវាត្រឡប់មកវិញ?

បញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតរបស់អ្នកនឹងពិនិត្យដើម្បីធានាថាវាត្រូវបានបំពេញត្រឹមត្រូវ។ បើវាដូច្នោះ ឈ្មោះរបស់អ្នកនឹងស្ថិតលើបញ្ជីនៃកន្លែងបោះឆ្នោតដែលអ្នកបានរស់នៅយ៉ាងហោចណាស់មួយខែ។ យើងនឹងផ្ញើជូនអ្នកនូវការជូនដំណឹងតាមសំបុត្រដើម្បីបញ្ជាក់ការចុះឈ្មោះរបស់អ្នក។

## ព័ត៌មានអ្វីដែលខ្ញុំត្រូវផ្តល់ឲ្យ?

សូមឆ្លើយសំណួរទាំងអស់លើទម្រង់បែបបទនៃការចុះឈ្មោះ ដូច្នេះយើងអាចចុះឈ្មោះអ្នកបានត្រឹមត្រូវ។ មានតែចំណុចដែលសម្គាល់ដោយសញ្ញាផ្កាយ (*) ប៉ុណ្ណោះ នឹងបោះពុម្ពក្នុងបញ្ជីបោះឆ្នោត។

*ឈ្មោះពេញរបស់អ្នក៖

នេះគឺចាំបាច់ដើម្បីពិនិត្យថាអ្នកបានចុះឈ្មោះត្រឹមត្រូវ និង ដើម្បីញែកឲ្យដាច់រវាងមនុស្សដែលមាននាមត្រកូលដូចគ្នា ឬ ឈ្មោះស្រដៀងគ្នា។

ថ្ងៃខែឆ្នាំកំណើត៖

នេះបង្ហាញជូនបញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតរបស់អ្នកថាអ្នកមានអាយុគ្រប់គ្រាន់ដើម្បីចុះឈ្មោះ និង អាចជួយយើងញែកឲ្យដាច់រវាងមនុស្សដែលមានត្រកូលដូចគ្នា។

ហត្ថលេខា និង កាលបរិច្ឆេទ៖

បើអ្នកគឺជាជនជាតិម៉ៅរីញូវសេឡេន ឬ កូនចៅរបស់ម៉ៅរីញូវសេឡេន អ្នកត្រូវតែចុះហត្ថលេខា និង កាលបរិច្ឆេទក្នុងផ្នែកម៉ៅរី ឬ ផ្នែកទូទៅ។ អ្នកមិនត្រូវចុះហត្ថលេខាលើក្រុមទាំងពីរឡើយ។
វាមានសារៈសំខាន់ដែលអ្នកជ្រើសរើសដោយយកចិត្តទុកដាក់ថាបញ្ជីណាដែលអ្នកចង់ស្ថិតនៅលើនោះ។ មនុស្សផ្សេងទៀតទាំងអស់ត្រូវតែចុះហត្ថលេខា និង កាលបរិច្ឆេទក្នុងផ្នែកទូទៅ។ បើអ្នកពិការខាងរាងកាយ ឬ ស្ថិតនៅបរទេស ពាក្យសុំអាចត្រូវបានចុះហត្ថលេខាក្នុងនាមអ្នក។

*អាសយដ្ឋានទីលំនៅ៖

នេះគឺជាអាសយដ្ឋាននៃគេហដ្ឋានរបស់អ្នក។ ប្រអប់ប្រៃសណីយ៍ញូវសេឡេន ឬ លេខចែកចាយនៅជនបទមិនគ្រប់គ្រាន់ដើម្បីពណ៌នាអាសយដ្ឋានរបស់អ្នកឡើយ។ យើងត្រូវការអាសយដ្ឋានគេហដ្ឋានពេញរបស់អ្នក ដូច្នេះយើងអាចចុះឈ្មោះឲ្យអ្នកក្នុងកន្លែងបោះឆ្នោតដែលអ្នក "ស្នាក់នៅ"។

អ្នក "ស្នាក់នៅ" កន្លែងដែលអ្នកជ្រើសរើសធ្វើជាគេហដ្ឋានរបស់អ្នក ដោយសារគ្រួសារ ឬ ទំនាក់ទំនងផ្ទាល់ខ្លួន ឬ ដោយសារមូលហេតុគ្រួសារ ឬ ផ្ទាល់ខ្លួនផ្សេងទៀត។ ដោយគ្រាន់តែអ្នកអាចអវត្តមានម្តងម្កាល ឬ បណ្តោះអាសន្នពីកន្លែងនោះ មិនមានន័យថាអ្នកមិនស្នាក់នៅទីនោះឡើយ។ ការអវត្តមានពីកន្លែងនៃទីលំនៅរបស់អ្នក ដោយសារការងារ ឬ ការអប់រំរបស់អ្នក (ឬ ការងារ ឬ ការអប់រំរបស់ប្តី/ប្រពន្ធរបស់អ្នក) មិនប៉ះពាល់លើវាឡើយ។
កត្តាសំខាន់បំផុតដើម្បីកំណត់អំពីកន្លែងដែលអ្នកស្នាក់នៅគឺកន្លែងដែលអ្នកជ្រើសរើសធ្វើជាគេហដ្ឋានរបស់អ្នក។

អាសយដ្ឋានប្រៃសណីយ៍៖

នេះត្រូវការ បើអាសយដ្ឋានប្រៃសណីយ៍របស់អ្នកខុសពីអាសយដ្ឋានទីលំនៅរបស់អ្នក។ យើងត្រូវសរសេរជូនអ្នកដើម្បីបញ្ជាក់ការចុះឈ្មោះរបស់អ្នក។

*មុខរបរ៖

នេះក៏ជួយយើងញែកឲ្យដាច់រវាងមនុស្សដែលមានឈ្មោះដូចគ្នាផងដែរ។ វាអាចលេចឡើងញឹកញាប់លើបញ្ជីដែលបានបោះពុម្ពក្នុងទម្រង់កាត់។

ធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតតាមអេឡិចត្រូនិកនាពេលអនាគត៖

បើអ្នកចង់ធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់អ្នកតាមអេឡិចត្រូនិកនាពេលអនាគត ដោយមិនបំពេញក្នុងទម្រង់បែបបទមួយទេ សូមគូសក្នុងរង្វង់ "បាទ/ចាស" និង ប្រាប់អាសយដ្ឋានអ៊ីមែលរបស់អ្នកក្នុងផ្នែក D នៅខាងខ្នងនៃទម្រង់បែបបទនេះ។

តើអ្នកជាជនជាតិម៉ៅរី?

មានតែម៉ៅរីញូវសេឡេន ឬ កូនចៅនៃម៉ៅរីញូវសេឡេនប៉ុណ្ណោះ អាចឆ្លើយសំណួរដោយការគូសក្នុងរង្វង់ "បាទ/ចាស"។ មនុស្សផ្សេងទៀតទាំងអស់ត្រូវតែគូសរង្វង់ "ទេ"។

លេខទូរស័ព្ទ៖

លេខទាំងនេះគឺត្រូវការក្នុងករណីយើងត្រូវទាក់ទងអ្នក។

គំនូសផែនទី៖

បើអ្នករស់នៅអាសយដ្ឋានដែលគ្មានលេខ គំនូសផែនទីដែលបង្ហាញទីកន្លែងនៃទីលំនៅរបស់អ្នកគឺត្រូវការដើម្បីជួយបង្កើតកន្លែងបោះឆ្នោតត្រឹមត្រូវរបស់អ្នក។

តើអ្នកបានផ្លាស់ប្តូរអាសយដ្ឋានរបស់អ្នកក្នុងពេលថ្មីៗនេះដែរឬទេ?

បើអ្នកបានរស់នៅអាសយដ្ឋានទីលំនៅបច្ចុប្បន្នរបស់អ្នកក្នុងរយៈពេលតិចជាងមួយខែ សូមបំពេញផ្នែកទាំងនេះ។

ជនជាតិញូវសេឡេននៅបរទេស៖

អ្នកត្រូវតែបំពេញក្នុងផ្នែកទាំងនេះ បើអ្នកស្ថិតនៅបរទេស។ សូមសរសេរពេលដែលអ្នកបានរស់នៅញូវសេឡេនចុងក្រោយ, ពេលដែលអ្នកបានផ្លាស់ទីទៅបរទេស និង អាសយដ្ឋានចុងក្រោយដែលអ្នកបានរស់នៅយ៉ាងតិចមួយខែ មុនពេលអ្នកចាកចេញពីញូវសេឡេន។

## ការចុះបញ្ជីរបស់ម៉ៅរី

### ជម្រើសបោះឆ្នោតរបស់ម៉ៅរ ី?

បើអ្នកគឺជាជនជាតិម៉ៅរីញូវសេឡេន ឬ កូនចៅរបស់ម៉ៅរីញូវសេឡេន អ្នកអាចជ្រើសស្ថិតនៅលើបញ្ជីម៉ៅរី ឬ ទូទៅ។

### ខ្ញុំគឺជាម៉ៅរីញូវសេឡេន។ តើខ្ញុំជ្រើសរើសបញ្ជីណាត្រូវស្ថិតនៅលើដូចម្ដេច?

ជាទូទៅ រៀងរាល់ប្រាំឆ្នាំម្ដង ជម្រើសបោះឆ្នោតរបស់ម៉ៅរីគឺផ្ញើទៅនរណាម្នាក់ដែលស្ថិតនៅលើបញ្ជីបោះឆ្នោតដែលបាននិយាយថាពួកគេគឺជា កូនចៅរបស់ជនជាតិម៉ៅរីញូវសេឡេន។ ទម្រង់បែបបទនេះត្រូវបានប្រើដើម្បីជ្រើសថាតើអ្នកចង់ស្ថិតនៅលើបញ្ជីម៉ៅរី ឬ បញ្ជីទូទៅ។ នេះគេហៅថាការអនុវត្តជម្រើសបោះឆ្នោតម៉ៅរី។

### ចុះបើខ្ញុំគឺជាម៉ៅរីដែលចុះឈ្មោះជាលើកដំបូង?

អ្នកអាចជ្រើសរើសប្រភេទនៃបញ្ជីណាដែលត្រូវស្ថិតនៅលើ បើអ្នកគឺជាជនជាតិម៉ៅរីញូវសេឡេន ដោយការចុះហត្ថលេខាលើផ្នែកដែលសមស្របលើទម្រង់បែបបទនៃការចុះឈ្មោះ។ នៅពេលអ្នកបានជ្រើសជម្រើសរបស់អ្នកហើយ អ្នកមិនអាចផ្លាស់ប្ដូរវិញឡើយ រហូតទាល់តែជម្រើសនៃការបោះឆ្នោតរបស់ម៉ៅរីបន្ទាប់អនុវត្ត។

### តើជម្រើសបោះឆ្នោតម៉ៅរីធ្វើឡើងញឹកញាប់ប៉ុណ្ណា?

ជម្រើសបោះឆ្នោតម៉ៅរីជាទូទៅធ្វើឡើងម្ដងរៀងរាល់ប្រាំឆ្នាំម្ដងក្នុងអំឡុងពេលបួនខែ បន្ទាប់ពីជំរឿនប្រជាជន និង ទីលំនៅ ហើយផ្ដល់ឱ្យអ្នកបោះឆ្នោតម៉ៅរី នូវឱកាសដើម្បីត្រួតពិនិត្យ និង ប្ដូរប្រភេទបញ្ជីដែលពួកគេបានចុះឈ្មោះលើនោះ។

### ខ្ញុំគឺជាជនជាតិប៉ូលីនេស៊ីរស់លើកោះផាស៊ីហ្វិក។ តើខ្ញុំអាចស្ថិតលើបញ្ជីម៉ៅរីដែរឬទេ??

ទេ។ វាគឺសម្រាប់តែម៉ៅរីញូវសេឡេន និងកូនចៅរបស់ម៉ៅរីញូវសេឡេនប៉ុណ្ណោះ។ ម៉ៅរីនៅលើកោះឃុក និង អ្នករស់លើដីកោះផាស៊ីហ្វិកផ្សេងទៀតដែលមានសិទ្ធិចុះឈ្មោះគឺស្ថិតនៅលើបញ្ជីទូទៅ។

ព័ត៌មានបន្ថែមអាចទទួលបានក្នុងកូនសៀវភៅរបស់យើងដែលមានចំណងជើងថា "Enrolling to vote as a New Zealand Māori" ("ការចុះឈ្មោះបោះឆ្នោតជាម៉ៅរីញូវសេឡេន")។

## បញ្ជីបោះឆ្នោត

### តើអ្វីជាបញ្ជីបោះឆ្នោតរដ្ឋសភា?

បញ្ជីគឺជាសៀវភៅដែលរាយមនុស្សគ្រប់គ្នានៅកន្លែងបោះឆ្នោតដែលបានចុះឈ្មោះ។ វារួមបញ្ចូលឈ្មោះរបស់ពួកគេ, អាសយដ្ឋានទីលំនៅ និង មុខរបរ។ គ្រប់គ្នាមានសិទ្ធិមើលវា។ បញ្ជីថ្មីមួយត្រូវបានផ្សព្វផ្សាយរៀងរាល់ឆ្នាំ លើកលែងតែឆ្នាំបោះឆ្នោតរដ្ឋសភា។ ក្នុងឆ្នាំទាំងនោះ មានបញ្ជីដែលបានបោះពុម្ពពីរ; បញ្ជីទីមួយគឺសម្រាប់ឱ្យគ្រប់គ្នាពិនិត្យថាពួកគេត្រូវបានរាយត្រឹមត្រូវឬទេ ហើយបញ្ជីទីពីរត្រូវបានប្រើនៅថ្ងៃបោះឆ្នោត។

### តើកន្លែងណាដែលខ្ញុំអាចឃើញបញ្ជីបោះឆ្នោត?

ការិយាល័យរបស់បញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតនីមួយៗ និង បណ្ណាល័យសាធារណៈមានបញ្ជីទាំងអស់សម្រាប់ញូវសេឡេន។ គ្រប់ PostShop ក៏មានឯកសារចម្លងនៃបញ្ជីទូទៅ និង ម៉ៅរី សម្រាប់តំបន់របស់ខ្លួនផងដែរ។ PostShops ធំៗជាច្រើនមានបញ្ជីសម្រាប់កន្លែងបោះឆ្នោតដែលនៅជិតនោះផងដែរ។

ជម្រើសផ្សេងទៀត អ្នកអាចពិនិត្យព័ត៌មានលម្អិតនៃការចុះឈ្មោះរបស់អ្នកលើវិបសៃរបស់យើង – elections.org.nz។

### តើព័ត៌មានបោះឆ្នោតប្រើសម្រាប់អ្វី?

នៅពេលអ្នកចុះឈ្មោះ មានតែឈ្មោះរបស់អ្នក, អាសយដ្ឋានទីលំនៅ

និង មុខរបរប៉ុណ្ណោះនឹងលេចឡើងលើបញ្ជីដែលបានបោះពុម្ពសម្រាប់កន្លែងបោះឆ្នោតរបស់អ្នក។ ឯកសារនេះគឺបើកចំហរចំពោះការត្រួតពិនិត្យដោយសាធារណជន។ ព័ត៌មាននេះរួមជាមួយក្រុមអាយុរបស់អ្នក, អាសយដ្ឋានប្រៃសណីយ៍ ឬ ព័ត៌មានរបស់កូនចៅម៉ៅរី (បើមាន) អាចត្រូវបានផ្ដល់ឱ្យអ្នកស្រាវជ្រាវវិទ្យាសាស្ត្រ ឬ សុខភាព, បេក្ខជន, សមាជិករដ្ឋសភា ឬ គណបក្សនយោបាយ។ ព័ត៌មាននេះក៏ត្រូវបានផ្ដល់ឱ្យទៅក្រុមប្រឹក្សាស្រុកសម្រាប់ការបោះឆ្នោតរបស់ពួកគេ និង គណៈសុខភាពស្រុក, ប្រជាមតិ និង ការបោះឆ្នោតនានាផងដែរ។ បញ្ជីនៃគណៈវិនិច្ឆ័យក៏ត្រូវបានចងក្រងដោយប្រើព័ត៌មានបោះឆ្នោតផងដែរ។

## ការរក្សាព័ត៌មានលម្អិតនៃការចុះឈ្មោះរបស់អ្នកឱ្យទាន់សម័យ

### តើខ្ញុំធ្វើអ្វី បើខ្ញុំប្ដូរអាសយដ្ឋានរបស់ខ្ញុំ?

មុនពេលអ្នកផ្លាស់ទីលំនៅ សូមបំពេញក្នុងទម្រង់បែបបទ "សំណើប្ដូរទិសដៅសំបុត្រ" នៃប្រៃសណីយ៍ញូវសេឡេន នៅ PostShop ណាមួយ។ អ្នកនឹងទទួលការចែកចាយសំបុត្ររបស់អ្នកទៅអាសយដ្ឋានថ្មីរបស់អ្នក ហើយបញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតរបស់អ្នកក៏នឹងទទួលដំណឹងថាអ្នកបានផ្លាស់ទីលំនៅផងដែរ។

បើអាសយដ្ឋានថ្មីរបស់អ្នកនៅតែស្ថិតនៅកន្លែងបោះឆ្នោតដដែល បញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតរបស់អ្នកនឹងធ្វើបច្ចុប្បន្នភាពបញ្ជីប៉ុណ្ណោះ និង ផ្ញើជូនអ្នកនូវសេចក្ដីជូនដំណឹងនៃការបញ្ជាក់ថ្មី។

ទោះជាយ៉ាងនេះក្ដី បើអ្នកបានផ្លាស់ទីលំនៅទៅក្នុងកន្លែងបោះឆ្នោតថ្មី អ្នកនឹងទទួលទម្រង់បែបបទនៃការចុះឈ្មោះជាបុគ្គលមុនបោះពុម្ពដើម្បីពិនិត្យ, ចុះហត្ថលេខា និង ផ្ញើត្រឡប់មកវិញ។ បន្ទាប់ពីបានទទួលទម្រង់បែបបទដែលអ្នកបានចុះហត្ថលេខា បញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតសម្រាប់កន្លែងបោះឆ្នោតថ្មីរបស់អ្នកនឹងចុះឈ្មោះអ្នក ហើយផ្ញើជូនអ្នកនូវសេចក្ដីជូនដំណឹងនៃការបញ្ជាក់។

បើបញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតមិនអាចរកឃើញឈ្មោះរបស់អ្នកលើបញ្ជីណាមួយទេ ពួកគេនឹងផ្ញើតាមសំបុត្រនូវទម្រង់បែបបទនៃការចុះឈ្មោះទៅអាសយដ្ឋានថ្មីរបស់អ្នក។

ជម្រើសផ្សេងទៀត អ្នកអាចបំពេញក្នុងទម្រង់បែបបទនៃការចុះឈ្មោះថ្មី ឬ ទៅវិបសៃរបស់យើង – elections.org.nz – និង ធ្វើបច្ចុប្បន្នភាពអាសយដ្ឋានរបស់អ្នកលើបណ្ដាញអ៊ីនធឺណិត។

### តើខ្ញុំត្រូវធ្វើអ្វី បើខ្ញុំប្តូរឈ្មោះ ឬ មុខរបររបស់ខ្ញុំ?

បើអ្នកប្តូរឈ្មោះ ឬ មុខរបររបស់អ្នក អ្នកគួរប្រាប់បញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតរបស់អ្នកជាលាយលក្ខណ៍អក្សរអំពីការផ្លាស់ប្តូរភ្លាមៗតាមដែលអាចធ្វើបាន។ ជម្រើសផ្សេងទៀត អ្នកអាចបំពេញក្នុងទម្រង់បែបបទនៃការចុះឈ្មោះថ្មី ឬ ធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់អ្នកលើវិបសៃរបស់យើង – elections.org.nz។

### តើអ្វីកើតឡើង បើខ្ញុំបានភ្លេចធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់ខ្ញុំ?

បើអ្នកភ្លេចធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់អ្នក យើងមិនអាចទាក់ទងអ្នកក្នុងអំឡុងយុទ្ធនាការធ្វើបច្ចុប្បន្នភាពនៃការចុះឈ្មោះឡើយ ហើយឈ្មោះរបស់អ្នកនឹងត្រូវបានលុបចេញពីបញ្ជី។ នោះ អ្នកនឹងត្រូវចុះឈ្មោះឡើងវិញ។

## យុទ្ធនាការធ្វើបច្ចុប្បន្នភាពនៃការចុះឈ្មោះ

### អ្វីជាយុទ្ធនាការធ្វើបច្ចុប្បន្នភាពនៃការចុះឈ្មោះ?

រៀងរាល់ឆ្នាំ ជនជាតិញូវសេឡេនរាប់ពាន់នាក់មានការផ្លាស់ប្តូរចំពោះជីវិតរបស់ពួកគេ។ ពួកគេផ្លាស់ទីលំនៅ, ពួកគេរៀបការ, ពួកគេផ្លាស់ប្តូរមុខរបររបស់ពួកគេ។ មនុស្សជាច្រើនត្រឡប់មកពីបរទេសវិញ។ ពេលខ្លះពួកគេមិនប្រាប់អំពីការផ្លាស់ប្តូរទាំងនេះចំពោះបញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតឡើយ។

ហេតុនេះហើយបានជាយើងមានយុទ្ធនាការធ្វើបច្ចុប្បន្នភាពនៃការចុះឈ្មោះក្នុងចន្លោះពេលទៀងទាត់មួយ។ បើចាំបាច់ គ្រប់គ្នាត្រូវពិនិត្យ និង ធ្វើបច្ចុប្បន្នភាពព័ត៌មានលម្អិតរបស់ពួកគេ ដូច្នេះបញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតអាចរួមបញ្ចូលការផ្លាស់ប្តូរទាំងអស់ក្នុងបញ្ជីបោះឆ្នោតថ្មីនោះ។

### តើខ្ញុំធ្វើអ្វី នៅពេលមានយុទ្ធនាការធ្វើបច្ចុប្បន្នភាពនៃការចុះឈ្មោះ?

អ្នកត្រូវពិនិត្យ និង កែ បើចាំបាច់ នូវព័ត៌មានលម្អិតនៃការចុះឈ្មោះរបស់អ្នក។ បញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតធ្វើឲ្យវាងាយស្រួលដោយការផ្ញើទម្រង់បែបបទមួយទៅគ្រប់គ្នាដែលស្ថិតលើបញ្ជីចាស់។ ទម្រង់បែបបទនៃការធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីរបស់អ្នកបង្ហាញព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់អ្នកដូចដែលវាបានកត់ត្រា។ មានកន្លែងដើម្បីឲ្យអ្នកធ្វើការកែ។ រួចហើយ អ្នកគ្រាន់តែចុះហត្ថលេខា និង កាលបរិច្ឆេទលើទម្រង់បែបបទនោះ និង ផ្ញើវាត្រឡប់មកវិញក្នុងស្រោមសំបុត្រឆ្លើយតបដែលបានផ្តល់ឲ្យ។ បើព័ត៌មានលម្អិតរបស់អ្នកទាំងអស់ត្រឹមត្រូវ អ្នកមិនចាំបាច់ឆ្លើយតបឡើយ ហើយអ្នកនឹងនៅតែបានចុះឈ្មោះជាមួយព័ត៌មានលម្អិតដែលបានបង្ហាញលើទម្រង់បែបបទបច្ចុប្បន្នភាពនៃការចុះឈ្មោះរបស់អ្នក។

### តើអ្វីកើតឡើង បើខ្ញុំមិនផ្ញើត្រឡប់ទៅវិញនូវទម្រង់បែបបទបច្ចុប្បន្នភាពនៃការចុះឈ្មោះរបស់ខ្ញុំ?

អ្នកនឹងនៅតែស្ថិតលើបញ្ជីជាមួយនឹងព័ត៌មានលម្អិតដូចគ្នាដែលបានបង្ហាញលើទម្រង់បែបបទបច្ចុប្បន្នភាពនៃការចុះឈ្មោះ។

### ចុះបើខ្ញុំទទួលទម្រង់បែបបទបច្ចុប្បន្នភាពនៃការចុះឈ្មោះសម្រាប់នរណាម្នាក់ដែលលែងរស់នៅអាសយដ្ឋាននោះ?

អ្នកគួរបញ្ជូនវាបន្តទៅពួកគេនៅអាសយដ្ឋានថ្មីរបស់ពួកគេ ឬ បើមិនស្គាល់ទេ សូមសម្គាល់លើស្រោមសំបុត្រថា “Gone no address” និង ផ្ញើវាត្រឡប់មកវិញតាមប្រៃសណីយ៍។ វានឹងផ្ញើត្រឡប់ទៅបញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតដែលនឹងលុបឈ្មោះរបស់បុគ្គលនោះពីបញ្ជី។

### ចុះបើខ្ញុំមិនទទួលទម្រង់បែបបទបច្ចុប្បន្នភាពនៃការចុះឈ្មោះ?

អ្នកត្រូវតែបំពេញក្នុងទម្រង់បែបបទនៃការចុះឈ្មោះថ្មី។ នៅពេលបញ្ជិកាក្រឹតនៃអ្នកបោះឆ្នោតរបស់អ្នកបានទទួលទម្រង់បែបបទនៃការចុះឈ្មោះដែលអ្នកបានបំពេញ ឈ្មោះរបស់អ្នកនឹងលេចឡើងលើបញ្ជីបោះឆ្នោត។

## ព្រំដែននៃការបោះឆ្នោត

### ខ្ញុំមិនបានផ្លាស់ទីលំនៅទេ ប៉ុន្តែខ្ញុំត្រូវបានដាក់ក្នុងកន្លែងបោះឆ្នោតផ្សេង។ ហេតុអ្វី?

កន្លែងបោះឆ្នោតនីមួយៗត្រូវតែមានចំនួននៃមនុស្សប្រហាក់ប្រហែលនឹងចំនួនមនុស្សនៅទីនោះ។ ប៉ុន្តែកន្លែងខ្លះអាចកើនឡើង ខណៈដែលកន្លែងផ្សេងទៀតអាចថយចុះ ហើយពេលខ្លះ ព្រំដែនត្រូវលៃតម្រូវ។

ជាទូទៅ រៀងរាល់ប្រាំឆ្នាំម្តង បន្ទាប់ពីជំរឿនប្រជាជន និង ទីលំនៅ ព្រំដែននៃកន្លែងបោះឆ្នោតទាំងអស់ត្រូវបានត្រួតពិនិត្យ។ បើមានការផ្លាស់ប្តូរចំនួនប្រជាជនច្រើនក្នុងកន្លែងបោះឆ្នោតមួយ ព្រំដែននោះអាចត្រូវផ្លាស់ប្តូរដើម្បីរក្សាឲ្យកន្លែងបោះឆ្នោតនោះមានចំនួននៃមនុស្សប្រហែលគ្នានឹងកន្លែងនោះ។

បន្ទាប់មក ព្រំដែនថ្មីទាំងនេះត្រូវបានប្រើសម្រាប់ការបោះឆ្នោតបន្ទាប់។

## ការបោះឆ្នោតផ្សេងទៀត

### តើអ្វីជាការបោះឆ្នោតពិសេសនៃរដ្ឋសភា?

ពេលខ្លះ កៅអីនៃមណ្ឌលបោះឆ្នោតក្នុងរដ្ឋសភាទំនេរនៅចន្លោះពេលនៃការបោះឆ្នោតទូទៅ។ នោះប្រជាជនក្នុងកន្លែងបោះឆ្នោតនោះមានឱកាសដើម្បីបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភាថ្មី។ នេះគេហៅថាការបោះឆ្នោតពិសេស។ បញ្ជីបោះឆ្នោតដែលបានធ្វើបច្ចុប្បន្នភាពនឹងបង្កើតឡើងសម្រាប់កន្លែងបោះឆ្នោតនោះ។

### អ្វីជាបោះឆ្នោតក្នុងស្រុក?

នៅពេលអ្នកចុះឈ្មោះជាអ្នកបោះឆ្នោតរដ្ឋសភា អ្នកក៏នឹងចុះឈ្មោះដោយស្វ័យប្រវត្តិសម្រាប់បញ្ជីក្រុមប្រឹក្សាស្រុករបស់អ្នកផងដែរ។ នេះមានន័យថា អ្នកក៏អាចបោះឆ្នោតក្រុមប្រឹក្សាស្រុករបស់អ្នក និង ការបោះឆ្នោតគណៈសុខភាពស្រុកផងដែរ។

នេះរួមបញ្ចូលទាំងការបោះឆ្នោតជ្រើសរើសអភិបាលក្រុង ឬ ស្រុករបស់អ្នក និង សមាជិកដើម្បីតំណាងឲ្យអ្នកនៅក្រុមប្រឹក្សាតំបន់របស់អ្នក, ក្រុមប្រឹក្សាទីក្រុង ឬ ស្រុក, គណៈសហគមន៍, គណៈសុខភាពស្រុក និង អង្គផ្សេងទៀតខ្លះ ដូចជាគណៈអភិបាលផ្តល់អាជ្ញាប័ណ្ណ។

### តើខ្ញុំទទួលសិទ្ធិបោះឆ្នោតក្នុងប្រជាមតិដែលផ្តួចផ្តើមដោយពលរដ្ឋ និង/ឬ ប្រជាមតិដែលផ្តួចផ្តើមដោយរដ្ឋាភិបាលដែរឬទេ?

នៅពេលអ្នកបានចុះឈ្មោះជាអ្នកបោះឆ្នោតរដ្ឋសភា អ្នកត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិដើម្បីបោះឆ្នោតប្រជាមតិដែលផ្តួចផ្តើមដោយពលរដ្ឋ និង/ឬ រដ្ឋាភិបាល។

## ព័ត៌មានបន្ថែមទៀត

### តើខ្ញុំទទួលព័ត៌មានបន្ថែមដូចម្តេច?

ព័ត៌មានបន្ថែមអំពីការចុះឈ្មោះបោះឆ្នោតអាចទទួលបានតាម៖

- ☐ ការមើលវិបសៃរបស់យើង – elections.org.nz
- ☐ ការហៅទូរស័ព្ទមកយើងដោយឥតបង់ប្រាក់តាមលេខ 0800 ENROL NOW (0800 36 76 56)
- ☐ ការអានកូនសៀវភៅ
  - Everything you need to know about the unpublished electoral roll (អ្វីៗដែលអ្នកត្រូវដឹងអំពីបញ្ជីបោះឆ្នោតដែលមិនបានផ្សព្វផ្សាយ)*
  - Enrolling to vote before you’re 18 (ការចុះឈ្មោះបោះឆ្នោត មុនពេលអ្នកមានអាយុ 18 ឆ្នាំ)*
  - Enrolling to vote as a New Zealand Māori (ការចុះឈ្មោះបោះឆ្នោតជាម៉ៅរីញូវសេឡែន)* កូនសៀវភៅនេះមានតែជាភាសាអង់គ្លេស និង ម៉ៅរីប៉ុណ្ណោះ។

* អាចទទួលបានពី PostShops ឬ ការិយាល័យរបស់បញ្ជិកាក្រឹតនៃអ្នកបោះឆ្នោត។

សូមអរគុណអ្នកចំពោះការអានកូនសៀវភៅនេះ។

យើងសង្ឃឹមថា កូនសៀវភៅនេះបានឆ្លើយសំណួររបស់អ្នកទាំងអស់អំពីការចុះឈ្មោះបោះឆ្នោត។

បើអ្នកត្រូវការជំនួយបន្ថែមទៀត សូមមើល ELECTIONS.ORG.NZ ឬ ហៅទូរស័ព្ទមកយើងដោយឥតបង់ប្រាក់តាម 0800 ENROL NOW (0800 36 76 56)

## តើខ្ញុំអាចទទួលព័ត៌មាននេះជាភាសាផ្សេងទៀតដែរឬទេ?

វិបសៃរបស់យើងមានកូនសៀវភៅនេះជាច្រើនភាសា។


Electoral Enrolment Centre
New Zealand Post Limited
P O Box 190
Wellington 6140

ទូរស័ព្ទ៖ 0800 ENROL NOW
(0800 36 76 56)
ទូរសារ៖ (04) 801 0709

អ៊ីមែល៖ enrol@elections.org.nz
វិបសៃ៖ elections.org.nz